# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Mar-2013, 14:58
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## សំណើសុំដាក់ឲ្យពិភាក្សាដេញដោលនូវបទសម្ភាសន៍ជាមួយព្រះបាទ នរោត្តម សីហនុ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង

---

<u>ដាក់ដោយ</u>៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

<u>ដាក់ជូន</u>៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ុំច ស្រីផាត

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្ដីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ សហព្រះរាជអាជ្ញាបានផ្ញើជូនភាគីនូវបញ្ជីឯកសារ ដែលខ្លួនមានបំណងបង្ហាញ នៅក្នុងសវនាការស្ដីពីតួនាទីរបស់លោក ខៀវ សំផន[1]។ ក្នុងចំណោមឯកសារ "គន្លឹះ" ទាំងនេះរបស់សហព្រះរាជអាជ្ញា មានចម្លើយសាក្សីដែលទទួលមរណភាព។

២. នៅថ្ងៃដដែលនោះ មេធាវីការពារក្ដីលោក ខៀវ សំផន បានជំទាស់ទៅនឹងការប្រើប្រាស់ចម្លើយសាក្សីពាក់ព័ន្ធនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ ប្រសិនបើសាក្សីរូបនោះមិនអាចមកផ្ដល់សក្ខីកម្មបាន។ មេធាវីការពារក្ដីបានជំទាស់ ជាអាទិ៍ ទៅនឹងការប្រើប្រាស់ចម្លើយរបស់ព្រះបាទ សម្ដេច នរោត្ដម សីហនុ ពាក់ព័ន្ធនឹងតួនាទីរបស់លោក ខៀវ សំផន។ មេធាវីការពារក្ដីបានរំឭកថា នៅពេលខ្លួនស្នើសុំស្ដាប់ចម្លើយ នៅពេលព្រះអង្គមានព្រះជន្ម សហព្រះរាជអាជ្ញាបានជំទាស់ ដោយសំអាងថាការស្ដាប់ចម្លើយនេះ *"គ្មានភាពពាក់ព័ន្ធ"*[2]។

៣. នៅក្នុងសវនាការថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ប្រធានអង្គជំនុំជម្រះបានច្រានចោលការជំទាស់របស់មេធាវីការពារក្ដី ដោយបញ្ជាក់ថា ចម្លើយសាក្សីដែលទទួលមរណភាព ដែលសហព្រះរាជអាជ្ញាមានបំណងដាក់ជូនអង្គជំនុំជម្រះ អាចជឿទុកចិត្តបាន និងមានភាពពាក់ព័ន្ធ។ ក៏ប៉ុន្តែ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ថា *"តម្លៃជាភស្តុតាងនៃចម្លើយទាំងនោះនឹងត្រូវវាយតម្លៃ ដោយផ្អែកលើកាលៈទេសៈ និងបទដ្ឋានផ្លូវច្បាប់ទាំងអស់ ដូចមានរៀបរាប់នៅក្នុងឯកសារ E96/7"*[3]។

៤. ក្នុងសវនាការដដែលនេះ សហព្រះរាជអាជ្ញាបានចាក់បញ្ចាំងខ្សែវីដេអូមួយដែលជាបទសម្ភាសន៍ជាមួយ សម្ដេច នរោត្ដម សីហនុ (ឯកសារ D299.1.42R)[4]។

---

[1] អ៊ីមែលរបស់លោក Tarik Abdulhak ផ្ញើជូនភាគី នៅថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ៩ និង ៤៩ នាទី កម្មវត្ថុ៖ *"ឯកសាររបស់សហព្រះរាជអាជ្ញាដែលត្រូវប្រើប្រាស់នៅក្នុងការបង្ហាញអំពីតួនាទីរបស់ ខៀវ សំផន"*។

[2] ប្រតិចារឹកសវនាការ ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/167.1 ទំព័រ ៦០ បន្ទាត់ ១៦-២៣ ទំព័រ ៦១ បន្ទាត់ ១៥។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/168.1 ទំព័រ ២ បន្ទាត់ ៨-១២។

[4] ប្រតិចារឹកសវនាការ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/168.1 ទំព័រ ១៨ បន្ទាត់ ៩-១២ ទំព័រ ១៩ បន្ទាត់ ១-២។

៥. ដើម្បីជួយដល់អង្គជំនុំជម្រះក្នុងការកំណត់តម្លៃជាភ័ស្តុតាងនៃខ្សែវីដេអូ ដែលសហព្រះរាជអាជ្ញាបានបង្ហាញ លោក ខៀវ សំផន ស្នើសុំដាក់ឲ្យពិភាក្សាដេញដោលនូវខ្សែវីដេអូមួយផ្សេងទៀតរបស់សម្តេច នរោត្តម សីហនុ ដែលមានខ្លឹមសារផ្ទុយគ្នាទាំងស្រុងនឹងខ្សែវីដេអូដែលបានបញ្ចាំងនៅក្នុងសវនាការ។ ខ្សែវីដេអូនេះមានប្រយោជន៍សម្រាប់ការវាយតម្លៃឲ្យសុក្រឹតលើចម្លើយ ដែលសហព្រះរាជអាជ្ញាចាត់ទុកថាជាភ័ស្តុតាងដ៏សំខាន់។ ខ្សែវីដេអូនេះមានភាពចាំបាច់ជាពិសេសសម្រាប់ស្វែងរកការពិត។

<u>**ច្បាប់ជាធរមាន**</u>

៦. វិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចែងថា *"ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាច (...) ទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"*។

៧. នៅក្នុងសេចក្តីសម្រេចលើឯកសារថ្មី អង្គជំនុំជម្រះបានប្រកាសថា៖ *"ចំពោះឯកសារទាំងអស់ដែលមិនមាននៅក្នុងបញ្ជីឯកសារដាក់ដោយភាគី ស្របតាមដីកានានារបស់អង្គជំនុំជម្រះ អង្គជំនុំជម្រះសូមបញ្ជាក់ថា ភាគីនៅតែមានលទ្ធភាពក្នុងការដាក់ពាក្យសុំបង្ហាញឯកសារថ្មីនាពេលក្រោយទៀតអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ប្រសិនបើភាគីយល់ឃើញថាឯកសារថ្មីដែលខ្លួនស្នើសុំដាក់នោះ ផ្តល់ប្រយោជន៍ដល់យុត្តិធម៌"*[5]។

<u>**ភាពអាចទទួលយកបាននៃសំណើ**</u>

៨. ខ្សែវីដេអូនេះជួយដល់ការស្វែងរកការពិត ហើយអង្គជំនុំជម្រះត្រូវតែទទួលយកខ្សែវីដេអូនេះ ដើម្បីជាប្រយោជន៍ដល់យុត្តិធម៌។

៩. ជាក់ស្តែង នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ នៅក្នុងខ្សែវីដេអូដែលសហព្រះរាជអាជ្ញាបានចាក់

---

[5] សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ ឯកសារ E190 កថាខណ្ឌ ២១។

បញ្ចាំង (ឯកសារ D299.1.42R) សម្ដេច នរោត្ដម សីហនុ បានមានព្រះបន្ទូលថា៖

*"ជាដំបូង ចាប់ពីខែ មេសា ឆ្នាំ ១៩៧៥ ដល់ខែ មេសា ឆ្នាំ ១៩៧៦ ក្នុងឋានៈជាប្រមុខរដ្ឋ ខ្ញុំបានធ្វើដំណើរទៅទូទាំងប្រទេសកម្ពុជា ជាមួយលោក ខៀវ សំផន។ ខ្ញុំឃើញថាសហករណ៍ជាជំរំប្រមូលផ្តុំ ខ្ញុំឃើញប្រជាជនធ្វើការទាំងថ្ងៃទាំងយប់។ នៅពេលព្រះចន្ទពេញវង់ ប្រជាជនមិនអាចដេកបានទេ ពួកគេមិនមានសិទ្ធិដេកទេ គឺត្រូវតែធ្វើការ។ ខ្ញុំឃើញការហូបចុករបស់ប្រជាជន គឺមិនមានបាយហូបទេ។ គេលាយបបរជាមួយបន្លែផ្សេងៗ លាយជាមួយដើមចេកហាន់ជាចំណិតតូចៗ"*[6]។

១០. បទសម្ភាសន៍នេះមិនមានបង្ហាញកាលបរិច្ឆេទនោះទេ។

១១. នៅក្នុងបទសម្ភាសន៍មួយទៀតដែលបានផ្ដល់ជូនទូរទស្សន៍បារាំង នៅថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ១៩៧៩ មានចំណងជើងថា *"នរោត្តម សីហនុ រៀបរាប់អំពីជីវិតរបស់ព្រះអង្គនៅក្នុងរបបខ្មែរក្រហម"* ព្រះអង្គមានព្រះបន្ទូលផ្ទុយស្រឡះលើប្រធានបទដដែល៖ *"ជាមួយ ខៀវ សំផន យើងបានដើរមើលតាមសហករណ៍ ស្រែចម្ការ ការដ្ឋានការងារ។ ពួកគេមិនលំបាកទេ ពួកគេមើលទៅគ្មានភាពតក់ស្លុតទេ។ ពួកគេមិនខ្វះអាហារហូបចុកនោះទេ"*[7]។

១២. គឺខ្សែវីដេអូនេះហើយ ដែលមេធាវីការពារក្ដីលោក ខៀវ សំផន ស្នើសុំដាក់ឲ្យពិភាក្សាដេញដោលដើម្បីឲ្យអង្គជំនុំជម្រះពិនិត្យរួមគ្នាជាមួយនឹងខ្សែវីដេអូដែលសហព្រះរាជអាជ្ញាបានបង្ហាញ នៅក្នុងសវនាការថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣។

១៣. មេធាវីការពារក្ដីលោក ខៀវ សំផន សូមបញ្ជាក់ថា តាមរយៈខ្សែវីដេអូ *"នរោត្តម សីហនុ រៀបរាប់អំពីជីវិតរបស់ព្រះអង្គនៅក្នុងរបបខ្មែរក្រហម"* អង្គជំនុំជម្រះនឹងមិនផ្ដល់តម្លៃជាភ័ស្តុតាងដល់ព្រះបន្ទូលរបស់ព្រះបរមសព នរោត្តម សីហនុ នៅក្នុងខ្សែវីដេអូដែលសហព្រះរាជអាជ្ញាបានបង្ហាញឡើយ។ ទោះជាយ៉ាងណាក៏ដោយ ខ្សែវីដេអូនេះអាចជួយដល់ការស្វែងរកការពិត ក្នុងករណីមិន

---

[6] ប្រតិចារឹកសវនាការ ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ឯកសារ E1/168.1 ទំព័រ ១៨ បន្ទាត់ ១៨-២២។

[7] ខ្សែវីដេអូនេះអាចរកបានទាំងស្រុង នៅលើវែបសាយត៍របស់វិទ្យាស្ថានជាតិសោតទស្សន៍បារាំង៖ « http://www.ina.fr/video/I06065624 »។ មេធាវីការពារក្ដីភ្ជាប់ប្រតិចារឹកវីដេអូទាំងមូល ជាមួយនឹងសំណើនេះ។

អាចសួរដេញដោលទាំងស្រុងទៅលើសាក្សីដែលទទួលមរណភាពទៅហើយនោះ។

១៤. នៅក្នុងសេចក្តីសម្រេចស្តីពីឯកសារថ្មី អង្គជំនុំជម្រះលើកឡើងនៅក្នុងកថាខណ្ឌមួយអំពី *"ចម្លើយរបស់សាក្សីដែលទទួលមរណភាពនៅក្នុងចន្លោះពេលនេះ"*[8]។ អង្គជំនុំជម្រះរំឭកថា ចម្លើយទាំងនេះអាចដាក់ឲ្យពិភាក្សាដេញដោលបាន ប្រសិនបើ *"សក្ខីកម្មដែលស្នើឡើងអាចជឿទុកចិត្តបាន និងក្នុងករណីដែលអង្គជំនុំជម្រះយល់ឃើញថា តម្លៃជាភស្តុតាងនៃចម្លើយដែលបានដាក់នៅក្នុងទម្រង់នេះ មិនទាបជាងលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌នោះទេ។"*

១៥. សហចៅក្រមស៊ើបអង្កេតមិនបានស្តាប់ចម្លើយសម្តេច នរោត្តម សីហនុ ទេ ហើយព្រះអង្គក៏មិនបានយាងមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះដែរ។ នៅក្នុងអត្ថបទសារព័ត៌មានមួយដែលបានចុះផ្សាយ ក្រោយពេលព្រះមហាក្សត្រ នរោត្តម សីហនុ យាងចូលទីវង្គត សាក្សីជាអ្នកជំនាញ Elisabeth BECKER បានចាត់ទុកព្រះអង្គជា *"ព្រះមហាក្សត្រដែលមានសម្ព័ន្ធភាពច្រើន" "មានសមត្ថភាពសម្រេចខាងនយោបាយដ៏អស្ចារ្យ"*[9]។ ខ្សែវីដេអូទាំងពីរនេះមានចម្លើយផ្ទុយគ្នា ហើយច្បាស់ណាស់ ត្រូវបានថតនៅក្នុងបរិបទនយោបាយផ្សេងគ្នា។ ក្នុងករណីគ្មានការសួរដេញដោលសាក្សី វាជារឿងអយុត្តិធម៌ពេញទី ហើយផ្ទុយនឹងផលប្រយោជន៍យុត្តិធម៌ ប្រសិនបើអង្គជំនុំជម្រះពិនិត្យមើលតែខ្សែវីដេអូដែលសហព្រះរាជអាជ្ញាបានបង្ហាញ។ វាជាប្រយោជន៍ដល់យុត្តិធម៌ ក្នុងការដាក់បញ្ចូលខ្សែវីដេអូធ្វើជាភស្តុតាង ដើម្បីឲ្យយល់ច្បាស់អំពីចម្លើយជាបន្តបន្ទាប់ និងផ្ទុយគ្នារបស់ព្រះបរមសព សម្តេច នរោត្តម សីហនុ។

១៦. ប្រឈមនឹងភាពមិនអាចកំណត់បានថាតើសេចក្តីថ្លែងការណ៍ណាមួយរបស់ព្រះបាទ នរោត្តម សីហនុ នៅក្នុងខ្សែវីដេអូទាំងពីរខាងលើនេះ អាចត្រូវបានចាត់ទុកថាជឿទុកចិត្តបាន និងជារឿងពិត មេធាវីការពារក្តីលោក ខៀវ សំផន លើកឡើងថា អង្គជំនុំជម្រះមានតែបដិសេធភស្តុតាងទាំងនេះនៅក្នុងការពិភាក្សាសម្រេចរបស់ខ្លួនប៉ុណ្ណោះ។

---

[8] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 កថាខណ្ឌ ៣២។

[9] អត្ថបទចុះផ្សាយក្នុងសារព័ត៌មាន ញូវយ៉ក ថាមស៍ និងប្រែសម្រួលដោយសារព័ត៌មាន Courrier international *"នរោត្តម សីហនុ ព្រះមហាក្សត្រដែលមានសម្ព័ន្ធភាពច្រើន"* ដោយ Elisabeth Becker ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០១២។

១៧. ប្រសិនបើអង្គជំនុំជម្រះមិនទទួលយកភ័ស្តុតាងថ្មីនេះទេ លោក ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះច្រានចោលខ្សែវីដេអូ D299.1.42R ដែលសហព្រះរាជអាជ្ញាបានចាក់បញ្ចាំង នៅក្នុងសវនាការថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣។ នេះជាលទ្ធភាពតែមួយគត់ក្នុងការធានាបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ចំពោះជនជាប់ចោទ ក្នុងករណីមិនអាចសួរដេញដោលសាក្សីទៅលើសម្តីផ្ទុយគ្នា ដែលបាននិយាយនៅខណៈពេលខុសគ្នា។

១៨. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

- **បង្គាប់** ឱ្យដាក់ពិភាក្សាដេញដោលនូវខ្សែវីដេអូ *"នរោត្តម សីហនុ រៀបរាប់អំពីជីវិតរបស់ព្រះអង្គនៅក្នុងរបបខ្មែរក្រហម"*
- **កត់សម្គាល់** ថាគ្មានតម្លៃជាភ័ស្តុតាងណាមួយត្រូវបានផ្តល់ដល់ព្រះបន្ទូលរបស់ព្រះបរមសពនរោត្តម សីហនុ នៅក្នុងខ្សែវីដេអូ D299.1.42R ដែលសហព្រះរាជអាជ្ញាបានចាក់បញ្ចាំង នៅក្នុងសវនាការថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ នោះទេ។

**ឬ៖**

- **ច្រានចោល** ខ្សែវីដេអូ D299.1.42R ដែលសហព្រះរាជអាជ្ញាបានចាក់បញ្ចាំង នៅក្នុងសវនាការថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | ទីក្រុងភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងភ្នំពេញ | |
| | មេធាវី Arthur VERCKEN | ទីក្រុងភ្នំពេញ | |
| | មេធាវី Jacques VERGÈS | ទីក្រុងប៉ារីស | |